ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះតុលាការកំពូល**

Supreme Court Chamber

Chambre de la Cour supreme

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក (១២)

Case File/Dossier N°. 002/19-09-2007-ECCC-TC/SC (12)

**ឯកសារដើម**
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-Apr-2012, 15:16
CMS/CFO: Kauv Keoratanak

**នៅចំពោះមុខ៖**

ចៅក្រម គង់ ស្រីម ប្រធាន

ចៅក្រម Motoo Noguchi

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Agniezska KLONOWIECKAMILART

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Chandra Nihal Jayasinghe

ចៅក្រម យ៉ា ណារិន

**កាលបរិច្ឆេទឯកសារ៖** ១៧ ខែ មេសា ឆ្នាំ ២០១២

**ភាសាដើម៖** ខ្មែរ/អង់គ្លេស

**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ

---

# សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីបណ្តឹងដិតចិត្តលោកស្រីចៅក្រម Silvia Cartwright

---

**ជនជាប់ចោទ៖**

អៀង សារី

**សហមេធាវីការពារក្តីជនជាប់ចោទ៖**

អាង ឧត្តម

Michael G. KARNAVAS

**សហព្រះរាជអាជ្ញា៖**

ជា លាង

Andrew CAYLEY

**មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួលបណ្តឹងសាទុក្ខភ្លាមៗរបស់ អៀង សារី ("ជនជាប់ចោទ") ជំទាស់ទៅនឹង"សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់ជនជាប់ចោទសុំឲ្យស៊ើបអង្កេត ពាក់ព័ន្ធទៅនឹងការជួបប្រជុំជាមួយ *តែភាគីម្ខាង* រវាង សហព្រះរាជអាជ្ញាអន្តរជាតិ Andrew Cayley និងលោកស្រីចៅក្រម CARTWRIGHT និងលោក Knut Rosandhaug អនុប្រធានរដ្ឋបាល ("កិច្ចប្រជុំជាមួយ*តែភាគីម្ខាង*")៖

## I. **ប្រវត្តិនីតិវិធី**

១ នៅថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចបដិសេធពាក្យសុំរបស់ នួន ជា ដែលបានដាក់ដោយអនុលោមតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុង និងពាក្យសុំរបស់ អៀង សារី ដែលបានដាក់អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង[1] ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំជាមួយ *តែភាគីម្ខាង* ("សេចក្តីសម្រេចដែលរងការជំទាស់")[2]។

២ នៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២ សហមេធាវីរបស់ជនជាប់ចោទ ("មេធាវីការពារក្តី") បានដាក់បណ្តឹងសាទុក្ខប្រឆាំងទៅនឹងសេចក្តីសម្រេចដែលរងការជំទាស់ ("បណ្តឹងសាទុក្ខ")[3]។ នៅថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានដាក់សារណាតប[4]។

---

[1] សំណើរបស់លោក អៀង សារី ស្នើឲ្យស៊ើបអង្កេត ពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងជាមួយតែភាគីម្ខាង រវាងសហព្រះរាជអាជ្ញាអន្តរជាតិ ជាមួយលោកស្រីចៅក្រម Cartwright និងអ្នកដទៃទៀត ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E137/3 ("សំណើ")។ បណ្តឹងជិតចិត្តជាបន្ទាន់ចំពោះចៅក្រម Cartwright ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E137/2។

[2] សេចក្តីសម្រេចលើបណ្តឹងជិតចិត្តចៅក្រម Silvia Cartwright ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារលេខ E137/5។

[3] បណ្តឹងសាទុក្ខរបស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើបណ្តឹងជិតចិត្តលោកស្រីចៅក្រម Silvia Cartwright ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២ ឯកសារលេខ E137/5/1/1។

[4] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំប្តឹងជិតចិត្តចៅក្រម Silvia Cartwright ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២ ឯកសារលេខ E137/5/1/2 ("ចម្លើយតប")។

## II. សេចក្តីសម្រេចដែលរងការជំទាស់ និងអំណះអំណាង

### ក. សេចក្តីសម្រេចដែលរងការជំទាស់

៣ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សំណើរបស់ជនជាប់ចោទ "មានខ្លឹមសារជាបណ្តឹងជិតចិត្ត"[5] ហើយបានពិចារណាលើមូលដ្ឋាននៃបណ្តឹងនេះ ដោយពុំបានយោងបន្ថែមទៀតទៅលើវិធានផ្ទៃក្នុង ៣៥ ឡើយ។ នៅក្នុងអង្គសេចក្តី អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា៖ សំណើទាំងពីរពុំបានបំពេញទៅតាមលក្ខខណ្ឌតម្រូវនៃភស្តុតាងដែលមានចែងនៅក្នុងវិធាន ៣៤ នៃវិធានផ្ទៃក្នុងឡើយ[6]។ កិច្ចប្រជុំដែលចោទជាបញ្ហានេះ គឺប្រហាក់ប្រហែលទៅនឹង "ក្រុមប្រឹក្សាសម្របសម្រួល" ដែលមាននៅតុលាការដទៃទៀត ហើយដែលជាការតម្រូវឱ្យបំពេញភារកិច្ច"ទទួលខុសត្រូវសំខាន់ៗផ្នែករដ្ឋបាល និងមិនពាក់ព័ន្ធនឹងតុលាការ"របស់អ្នកចូលរួម[7]។ កិច្ចប្រជុំទាំងនោះ មិនត្រូវបានហាមឃាត់ដោយក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក ឡើយ[8] ហើយ លោក Rosandhaug ក៏បានផ្តល់នូវសេចក្តីបញ្ជាក់យ៉ាងគ្រប់គ្រាន់រួចហើយ ទាក់ទិននឹងគោលបំណងនៃកិច្ចប្រជុំទាំងនោះ នៅក្នុងអ៊ីមែលមួយឆ្លើយតបទៅនឹងសំណើសុំព័ត៌មានបឋមរបស់ អៀង សារី និង នួន ជា[9]។ ដូចដែលមានការពន្យល់នៅក្នុងអ៊ីមែលរបស់លោក Rosandhaug អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា "បញ្ហាដែលយកមកពិភាក្សានៅក្នុងកិច្ចប្រជុំទាំងនេះ ពាក់ព័ន្ធនឹងបញ្ហាប្រតិបត្តិដែលប៉ះពាល់ដល់សមាសភាពអន្តរជាតិរបស់ អ.វ.ត.ក"[10]។

### ខ. អំណះអំណាងលើភាពអាចទទួលយកបាន

៤ មេធាវីការពារក្តីលើកឡើងថា បណ្តឹងសាទុក្ខអាចទទួលយកបាន អនុលោមតាមវិធាន ១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុង ដែលជាបណ្តឹងសាទុក្ខពាក់ព័ន្ធនឹងសេចក្តីសម្រេចលើការជ្រៀតជ្រែកទៅក្នុងកិច្ច

---

[5] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១២។

[6] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៩។

[7] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៩-២០។

[8] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២១។

[9] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២០។

[10] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២០។

ការរដ្ឋបាលរបស់តុលាការ អនុលោមតាមវិធាន ៣៥(៦) នៃវិធានផ្ទៃក្នុង[11]។ មេធាវីការពារក្ដីអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ឬនិយាយម្យ៉ាងទៀត អង្គជំនុំជម្រះនេះបានរំលោភអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ដោយចាត់ទុកសំណើសុំនេះជាបណ្ដឹងជិតចិត្ត ស្របតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុង ជាជាងសំណើសុំឲ្យស៊ើបអង្កេត អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងទៅវិញ[12]។

៥ សហព្រះរាជអាជ្ញាបានឆ្លើយតបថា បណ្ដឹងសាទុក្ខនេះគួរតែត្រូវបានចាត់ទុកថាមិនអាចទទួលយកបាន និងគ្មានមូលដ្ឋានជាក់ស្ដែង ដោយហេតុថា បណ្ដឹងសាទុក្ខនេះគ្មានពាក់ព័ន្ធនឹងបញ្ហាដែលជាកម្មវត្ថុនៃបណ្ដឹងសាទុក្ខភ្លាមៗ ដូចមានចែងក្នុងវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុងឡើយ ហើយបណ្ដឹងសាទុក្ខនេះ ខកខានមិនបានបង្ហាញឲ្យឃើញ*នូវសេចក្ដីបញ្ជាក់ដំបូង* ដើម្បីធ្វើជាយុត្តិកម្មសម្រាប់ឲ្យមានកិច្ចស៊ើបសួរណាមួយតាមវិធាន ៣៥ នោះទេ[13]។ សហព្រះរាជអាជ្ញាលើកឡើងថា នេះជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកំណត់ចរិតលក្ខណៈរបស់សំណើ ដូចដែលមានចែងនៅក្នុងវិធាន ៣៤ នៃវិធានផ្ទៃក្នុង និងបានកត់សម្គាល់ថា "នៅក្នុងផ្នែកដែលនិយាយអំពី"ច្បាប់ជាធរមាន" [នៃសំណើបឋម] ពុំឃើញមេធាវីការពារក្ដី អៀង សារី បញ្ជាក់ ឬលើកសំអាងទៅលើវិធាន ៣៥ ទាល់តែសោះ"[14]។

## គ. <u>អំណះអំណាងនៅក្នុងអង្គសេចក្ដី</u>

៦ មេធាវីការពារក្ដីលើកឡើងថា ដោយសារតែកិច្ចប្រជុំរវាងលោកស្រីចៅក្រម Cartwright និងលោក Cayley ពុំមានមូលដ្ឋានផ្លូវច្បាប់ច្បាស់លាស់ ហើយលោក Cayley ធ្លាប់ និងបន្តបង្ហាញខ្លួននៅចំពោះមុខលោកស្រីចៅក្រម Cartwright នៅក្នុងសំណុំរឿង ០០២ ទៀតនោះ អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកអង្គច្បាប់ ដោយពុំបានសម្រេចថា ការប្រាស្រ័យទាក់ទងបែបនេះ គឺជាការរំលោភទៅលើបទដ្ឋានផ្នែកក្រមសីលធម៌ជាធរមាន[15]។ យោងទៅលើមេធាវីការពារក្ដី

---

[11] បណ្ដឹងសាទុក្ខ កថាខណ្ឌ ៧។

[12] បណ្ដឹងសាទុក្ខ កថាខណ្ឌ ៥។

[13] ចម្លើយតប កថាខណ្ឌ ២១។

[14] ចម្លើយតប កថាខណ្ឌ ១៥។

[15] បណ្ដឹងសាទុក្ខ កថាខណ្ឌ ២៩-៣៩។

ការរំលោភបែបនេះ គឺគ្រប់គ្រាន់ក្នុងការបំពេញទៅតាម"លក្ខខណ្ឌកម្រិតទាបបំផុត" នៃ"ហេតុផលដែលអាចឲ្យជឿបាន"ថា មានការកើតឡើងនូវការជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលតុលាការ[16]។ មេធាវីការពារក្ដីកត់សម្គាល់ថា "មិនមានអ្វីដែលមិនសមស្រប ត្រូវបានលើកមកពិភាក្សាក្នុងអំឡុងពេលកិច្ចប្រជុំទាំងនេះឡើយ" ប៉ុន្តែ យ៉ាងហោចណាស់ កិច្ចប្រជុំ*តែភាគីម្ខាង* បង្ហាញឱ្យឃើញថា មានការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការដោយចេតនាពិតប្រាកដ[17]។

៧ មេធាវីការពារក្ដីលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងយល់ឃើញមិនត្រឹមត្រូវឡើយដែលថា កិច្ចប្រជុំទាំងនោះមានលក្ខណៈចាំបាច់សម្រាប់សមាសភាពអង្គការសហប្រជាជាតិ ពីព្រោះការទទួលខុសត្រូវដែលមិនមែនជាកិច្ចការតុលាការ ឬជាផ្នែករដ្ឋបាលរបស់លោកស្រីចៅក្រម Cartwright និងរបស់លោក Cayley ក្ដី សុទ្ធតែមិនផ្ដល់យុត្តិកម្មដល់កិច្ចប្រជុំ*តែភាគីម្ខាង*ទាំងនេះទេ។ ប្រសិនបើការសម្រប សម្រួលរវាងមន្ត្រីអង្គការសហប្រជាជាតិនៅ អ.វ.ត.ក ជាការចាំបាច់មែននោះ ការសម្របសម្រួលគួរតែត្រូវរៀបចំ ស្របទៅនឹងក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក ដែលហាមឃាត់មិនឲ្យ មានការប្រាស្រ័យទាក់ទង*តែភាគីម្ខាង*ឡើយ[18]។ អនុលោមតាមវិធានផ្ទៃក្នុង មុខងាររដ្ឋបាលដែលលើកយកមកពិភាក្សាតាមក្នុងកិច្ចប្រជុំរវាងលោកស្រីចៅក្រម Cartwright និងលោក Cayley គឺជាមុខងាររបស់គណៈកម្មាធិការរដ្ឋបាលតុលាការ ("JAC") និងការិយាល័យរដ្ឋបាល។ ប្រសិនបើចាំបាច់ ក្រុមប្រឹក្សាសម្របសម្រួលអាច"ត្រូវបានបង្កើតឡើងប្រកបដោយតម្លាភាពស្របតាមវិធានផ្ទៃក្នុង"[19]។ មេធាវីការពារក្ដីលើកឡើងថា កិច្ចប្រជុំដែលចោទជាបញ្ហាទាំងនោះ មានលក្ខណៈខុសគ្នាពីក្រុមប្រឹក្សាសម្របសម្រួលនៅតុលាការផ្សេងៗទៀត ពីព្រោះលោក Cayley នៅពេលបច្ចុប្បន្ននេះ កំពុងមានវត្តមាននៅចំពោះមុខ លោកស្រីចៅក្រម Cartwright និងដោយសារតែវិធាន និងបញ្ញត្តិនៅតុលាការ បានចែងអំពីក្រុមប្រឹក្សានេះដែរ[20]។

---

[16] បណ្ដឹងសាទុក្ខ កថាខណ្ឌ ១១។

[17] បណ្ដឹងសាទុក្ខ កថាខណ្ឌ ៣០។

[18] បណ្ដឹងសាទុក្ខ កថាខណ្ឌ ២-៣។

[19] បណ្ដឹងសាទុក្ខ កថាខណ្ឌ ៣៤។

[20] បណ្ដឹងសាទុក្ខ កថាខណ្ឌ ៣៦។

៨ មេធាវីការពារក្តីស្នើថា អង្គជំនុំជម្រះតុលាការកំពូលគួរតែមោឃៈសេចក្តីសម្រេចដែលរងការជំទាស់នេះ និងបង្គាប់ឲ្យធ្វើការស៊ើបអង្កេត ដោយអនុលោមតាមវិធាន ៣៥(២)[21] នៃវិធានផ្ទៃក្នុង។ មេធាវីការពារក្តីបានស្នើសុំឲ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈផងដែរ អនុលោមតាមវិធាន ១០៩(១) នៃវិធានផ្ទៃក្នុង[22]។

៩ សហព្រះរាជអាជ្ញាបានឆ្លើយតបថា មេធាវីការពារក្តីមិនបានបំពេញទៅតាមបន្ទុកបង្ហាញភស្តុតាងអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពីព្រោះថា វិធាននេះតម្រូវឱ្យមានមូលដ្ឋានជាសត្យានុម័តដែលគាំទ្រដល់ធាតុផ្សំជាសត្យានុម័ត និងធាតុផ្សំខាងស្មារតី[23] មិនមែនគ្រាន់តែជាការប៉ាន់ស្មាននោះទេ។ ពុំមានភស្តុតាងជាសត្យាម័តដែលបង្ហាញឲ្យឃើញថា កិច្ចប្រជុំទាំងនោះបានជ្រៀតជ្រែកចូលទៅក្នុងកិច្ចការរដ្ឋបាលតុលាការនៅក្នុងសំណុំរឿង ០០២ ឡើយ ហើយលើសពីនេះទៀត មេធាវីការពារក្តីពុំបានលើកឡើងនូវទង្វើករណ៍ណាមួយដែលថា មានធាតុផ្សំខាងស្មារតីដែលតម្រូវឲ្យមានចាំបាច់នោះឡើយ[24]។ លើសពីនេះទៀត កិច្ចការនានា ដែលអនុវលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង គឺជាឆន្ទានុសិទ្ធិ[25]។

១០ ចុងក្រោយ សហព្រះរាជអាជ្ញាលើកឡើងថា ការប្រាស្រ័យទាក់ទងទាំងនោះគឺ "ជាការចាំបាច់ និងសមស្របនៅក្នុងបរិបទនៃតុលាការព្រហ្មទណ្ឌអន្តរតួបនីយកម្ម"[26]។ សហព្រះរាជអាជ្ញា លើកឡើងថា ក្រមវិជ្ជាជីវៈតុលាការរបស់ អ.វ.ត.ក[27] មិនបានហាមឃាត់កិច្ចប្រជុំបែបនោះទេ ហើយថា កិច្ចប្រជុំបែបនោះឆ្លុះបញ្ចាំងនូវទម្លាប់នៃការអនុវត្តល្អៗរបស់តុលាការ និងសាលាក្តីអន្តរជាតិ និងអន្តរតួបនីយកម្មផ្សេងៗទៀត[28]។ ដូច្នេះ សហព្រះរាជអាជ្ញាស្នើសុំឲ្យបដិសេធបណ្តឹងសាទុក្ខនេះ។

---

[21] បណ្តឹងសាទុក្ខ កថាខណ្ឌ ១។

[22] បណ្តឹងសាទុក្ខ កថាខណ្ឌ ១២។

[23] ចម្លើយតប កថាខណ្ឌ ១៨។

[24] ចម្លើយតប កថាខណ្ឌ ១៩។

[25] ចម្លើយតប កថាខណ្ឌ ១៧។

[26] ចម្លើយតប កថាខណ្ឌ ២២។

[27] ក្រមវិជ្ជាជីវៈតុលាការរបស់ អ.វ.ត.ក មាត្រា ១, ២។

[28] ចម្លើយតប កថាខណ្ឌ ២៤។

## III. ការពិភាក្សា

### ក. ភាពអាចទទួលយកបាន

១១ វិធាន ១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុង បានកំណត់យ៉ាងច្បាស់អំពីយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល ទៅលើបណ្តឹងសាទុក្ខពីសេចក្តីសម្រេចនានា អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង។ ផ្ទុយទៅវិញ វិធាន ១០៤ នៃវិធានផ្ទៃក្នុង ពុំបានបញ្ជាក់អំពីបណ្តឹងសាទុក្ខពីសេចក្តីសម្រេចលើបណ្តឹងដិតចិត្ត អនុលោមតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុងឡើយ ដែលប្រការនេះត្រូវបានរារាំងយ៉ាងច្បាស់លាស់បន្ថែមទៀត តាមរយៈវិធានផ្ទៃក្នុង ៣៤(៨) នៃវិធានផ្ទៃក្នុង។ ដូច្នេះ បណ្តឹងសាទុក្ខនេះអាចទទួលយកបាន ប្រសិនបើសំណើសុំអាចត្រូវបានកំណត់ចរិតលក្ខណៈ យ៉ាងហោចណាស់ក្នុងផ្នែកខ្លះ ថាជាសំណើសុំធ្វើការស៊ើបអង្កេតប៉ុណ្ណោះ អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងនោះ។

១២ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា សំណើសុំនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបានយោងតិចតួចទៅលើវិធាន ៣៥ នៃវិធានផ្ទៃក្នុង ហើយពិតណាស់បានលើកឡើងនូវវិធាន ៣៤ នៃវិធានផ្ទៃក្នុង មិនមែនវិធាន ៣៥ ឡើយ ថា ជា"ច្បាប់ដែលអាចអនុវត្តបាន"ចំពោះកិច្ចដំណើរការនីតិវិធី[29]។ ទោះបីជាយ៉ាងណាក៏ដោយ សំណើនេះបានស្នើសុំឱ្យមានការស៊ើបអង្កេតអនុលោមតាមវិធាន ៣៥(២)[30] នៃវិធានផ្ទៃក្នុង និងគួរតែត្រូវចាត់ទុកថា អាចទទួលយកបាន លើកលែងតែសំណើសុំនោះបង្ហាញអំពីទឡ្ហីករណ៍នានា ដែលជាក់ស្តែងមិនអាចយកមកអនុវត្តបានតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង[31]។

១៣ អនុលោមតាមយុត្តិសាស្ត្ររបស់ អ.វ.ត.ក ការយកវិធាន ៣៥ នៃវិធានផ្ទៃក្នុង មកអនុវត្តចំពោះអំពើរបស់ តុលាការត្រូវបានរឹតត្បិតយ៉ាងខ្លាំង។ អង្គបុរេជំនុំជម្រះធ្លាប់បានបដិសេធមិនផ្តួចផ្តើមធ្វើការស៊ើបអង្កេត អនុលោមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ទៅលើការចោទប្រកាន់នានាដែលថា

---

[29] សំណើ កថាខណ្ឌ ១៣-២២។

[30] សំណើ បុព្វកថា កថាខណ្ឌ ១។

[31] សូមមើល ឧទាហរណ៍ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខ របស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យជនជាប់ចោទមានវត្តមានក្នុងសាលសវនាការ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១២ ឯកសារលេខ E130/4/3 ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង")។

សេចក្ដីសម្រេចរបស់តុលាការត្រូវបានរងឥទ្ធិពលដោយមិនត្រឹមត្រូវ ដោយយល់ឃើញថា អង្គជំនុំជម្រះរបស់ អ.វ.ត.ក ពុំមានយុត្តាធិការដើម្បីកំណត់ថាតើ "កិច្ចការតាមផ្លូវតុលាការ" គឺជាការជ្រៀតជ្រែកចូលទៅក្នុងកិច្ចការរដ្ឋបាលតុលាការ អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដែរ ឬយ៉ាងណានោះឡើយ[32]។ អង្គបុរេជំនុំជម្រះបានយល់ឃើញទៀតថា "អង្គជំនុំជម្រះនីមួយៗរបស់ អ.វ.ត.ក មិនមានយុត្តាធិការដោះស្រាយលើកំហុសចៅក្រមណាម្នាក់របស់ អ.វ.ត.ក ហួសពីការកម្រិតរបស់វិធាន ៣៤ នៃវិធានផ្ទៃក្នុងឡើយ[33]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការសម្រេចរបស់តុលាការដែលមានកំហុស គឺមិនគ្រប់គ្រាន់តាមផ្លូវច្បាប់ដើម្បីបំពេញនូវបទដ្ឋានស្របតាមវិធាន ៣៥ ឡើយ[34]។ ពុំឃើញមានយុត្តិសាស្ត្រណាមួយនៅតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងៗទៀត ដែលអនុវត្តការដាក់ទណ្ឌកម្ម ឬការដាក់វិន័យណាមួយទៅលើចៅក្រម អនុលោមតាមបទប្បញ្ញត្តិស្រដៀងគ្នាទៅនឹងវិធាន ៣៥ ឡើយ។

១៤ នៅក្នុងករណីនីមួយៗនៃរឿងក្ដីទាំងនេះ អង្គជំនុំជម្រះរបស់ អ.វ.ត.ក បានបដិសេធមិនអនុវត្តវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចំពោះទង្វើនៃការផ្ដល់មតិយោបល់តុលាការនោះទេ។ ប៉ុន្តែ ពុំមានយុត្តិសាស្ត្រណាមួយបញ្ជាក់ឲ្យបានច្បាស់លាស់ ថាតើចៅក្រមមិនស្ថិតក្រោមយុត្តាធិការ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដែរ ឬយ៉ាងណានោះទេ ឬថាតើការប្រព្រឹត្តណាខ្លះរបស់តុលាការ មិនស្ថិតក្រោមយុត្តាធិការលើកម្មវត្ថុនៃបទប្បញ្ញត្តិនោះទេ។ នៅក្នុងករណីនោះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ភាសានៃវិធាន ៣៥ នៃវិធានផ្ទៃក្នុង មិនបានបង្ហាញករណីលើកលែងច្បាស់លាស់ចំពោះប្រភេទនៃបុគ្គលណាខ្លះនោះទេ ហើយត្រូវអនុវត្តចំពោះ"ជនណាម្នាក់"នោះទេ។ ផ្ទុយមកវិញ តាមរយៈការបញ្ជាក់អំពីខ្លឹមសារនៃ"ការជ្រៀតជ្រែក ចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ" នៅក្នុងអនុវិធាន (ក) ដល់ (ង) នៃវិធានផ្ទៃក្នុង បានចែងយ៉ាងច្បាស់អំពីការកំណត់លើដែននៃ

---

[32] សាលដីកាលើបណ្ដឹងសាទុក្ខប្រឆាំងទៅនឹងដីកាសម្រេចលើសំណើលើកទីពីររបស់លោក នួន ជា សុំឲ្យបំពេញកិច្ចស៊ើបសួរ (វិធាន ៣៥) ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១០ ឯកសារលេខ D364/5/2 កថាខណ្ឌ ៣១ (អង្គបុរេជំនុំជម្រះមិនមានយុត្តាធិការសម្រេចថាតើ កិច្ចតាមផ្លូវតុលាការ (...) ខ្លួនឯងនេះ បាន ឬមិនបានបំពេញលក្ខខណ្ឌអប្បបរមាក្នុងការ ផ្ដួចផ្ដើមការស៊ើបអង្កេតតាមវិធានផ្ទៃក្នុង ៣៥(២)(ខ)")។

[33] សាលដីកាលើពាក្យសុំតាមវិធាន ៣៥ របស់លោកអៀង សារី សម្រាប់ការប្ដឹងជិតចិត្តចៅក្រម Marcel Lemonde សំណុំរឿងលេខ ០០២/០៧-១២-២០០៩-អវតក/អបជ (០៦) ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១០ ឯកសារលេខ ៥ ERN 00486637-00486642 កថាខណ្ឌ ១១។

[34] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង។

អំពីដែលអង្គជំនុំជម្រះត្រូវអនុវត្ត។ ហេតុដូច្នេះ ជាគោលការណ៍ ចៅក្រម យ៉ាងហោចណាស់ ស្ថិតនៅក្នុងយុត្តាធិការនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដែលបានចែងថា ការប្រព្រឹត្តរបស់ចៅក្រម ឈានទៅដល់កម្រិតនៃការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ យោងតាម ខ្លឹមសារនៃវិធាននេះ។

១៥ អត្ថិភាពនៃនីតិវិធីប្ដឹងជំទាស់ផ្អែកតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុង មិនបានរារាំងការអនុវត្តវិធាន ៣៥ នៃវិធានផ្ទៃក្នុងចំពោះចៅក្រមនោះទេ។ ទោះបីជាវិធាន ៣៤ នៃវិធានផ្ទៃក្នុង គឺជានីតិវិធីពិសេសមួយដែលមានគោលបំណងធានានូវសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និង សុចរិតភាពនៃតួនាទីតុលាការ វិធាន ៣៥ គឺជាបទប្បញ្ញត្តិទូទៅមួយ ដែលបង្កើតប្រភេទមួយចំនួន នៃទង្វើដែលហាមឃាត់។ អាស្រ័យហេតុនេះ នីតិវិធីទាំងពីរនេះ បានការពារតម្លៃគតិយុត្តផ្សេងៗគ្នា។ ភាគីមួយដែលដាក់បណ្ដឹងផ្អែកតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុង ត្រូវតែបង្ហាញថា ចៅក្រម មិនអាចដោះស្រាយបញ្ហាជម្លោះដោយឥតលម្អៀងបានឡើយ ឬមានការលេចឡើងច្បាស់លាស់អំពីភាពគ្មានអនាគតិនៅក្នុងរឿងក្ដីនេះ[35]។ ផ្អែកតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង សំណួរ គឺថាតើបទល្មើសប្រឆាំងនឹងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ត្រូវបានប្រព្រឹត្តឡើងដែរឬយ៉ាងណា។ ការយល់ឃើញដែលថា បទដ្ឋានតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុង ត្រូវបានបំពេញនោះ មិនតម្រូវឲ្យសម្រេចអំពីការប្រព្រឹត្តមិនត្រឹមត្រូវទៅលើសំណាក់ចៅក្រមនោះទេ។ បន្ថែមពីលើនេះ បទដ្ឋាននៃការបង្ហាញភស្តុតាង[36] និងផលវិបាកដែលអាចមាន[37] នៃបណ្ដឹងដែលបានអាចទទួលយកបាននោះ

---

[35] *រឿងក្ដី រដ្ឋអាជ្ញា តទល់ Furundžija*"សាលដីកា" របស់អង្គជំនុំជម្រះតុលាការកំពូល(IT-95-17/1-A) ចុះថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០០០ ("សាលដីកាលើរឿងក្ដី *Furundžija*") កថាខណ្ឌ ១៨៩។ សេចក្ដីសម្រេចលើបណ្ដឹងរបស់លោកអៀងសារីដែលប្ដឹងជំទាស់ចំពោះលោកចៅក្រម និល ណុន និងសំណើពាក់ព័ន្ធផ្សេងៗ ចុះថ្ងៃទី ២៨ ខែមករាឆ្នាំ ២០១១ ឯកសារ E5/3 កថាខណ្ឌ ៧។

[36] ប្រៀបធៀបវិធាន ៣៥(២) (សហចៅក្រមស៊ើបអង្កេតឬអង្គជំនុំជម្រះអាចបំពេញកិច្ចបន្ថែមដោយរួមបញ្ចូលទាំងការស៊ើបអង្កេត ប្រសិនបើមាន "ហេតុផលជឿ" ថាមានកើតនូវការបំពារបំពានលើវិធាន ៣៥(១)) ជាមួយនឹងសេចក្ដីសម្រេចលើសំណើរបស់ជនត្រូវចោទអៀងសារី សុំឲ្យមានវិធានការសមរម្យពាក់ព័ន្ធនឹងសេចក្ដីថ្លែងការណ៍មួយចំនួន ដែលធ្វើដោយសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានតតាំងនឹងឯករាជ្យភាពរបស់ចៅក្រមអង្គបុរេជំនុំជម្រះចៅក្រម Katinka LAHUIS និងចៅក្រម Rowan DOWNING សំណុំរឿងលេខ ០០២/២០-១០-២០០៩-អវតក/កសចស (អ.ប.ជ ០៣) ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារលេខ ៥ ERN 00404595-00404601 ("សេចក្ដីសម្រេចលើពាក្យសុំវិធានការសមស្រប") កថាខណ្ឌ ៨

មានលក្ខណៈខុសគ្នា។ ជាចុងក្រោយ ផ្អែកតាមទ្រឹស្តី ទោះបីជាការប្រព្រឹត្តរបស់ចៅក្រម អាចពាក់ព័ន្ធទាំងវិធាន ៣៤ នៃវិធានផ្ទៃក្នុងផង និងវិធាន ៣៥ នៃវិធានផ្ទៃក្នុង ក៏ដោយ ក៏ករណីនេះមិនមានអ្វីខុសប្លែកគ្នានោះដែរ។ មេធាវីនៅ អ.វ.ត.ក ត្រូវបានហាមឃាត់ប្រហាក់ប្រហែលគ្នាដែរ ដោយបទប្បញ្ញត្តិទូទៅនៅក្នុងវិធាន ៣៥ នៃវិធានផ្ទៃក្នុង និងបទបញ្ជាជាក់លាក់ដែលអនុវត្តចំពោះមេធាវីដែលមានចែងនៅក្នុងវិធាន ៣៨ នៃវិធានផ្ទៃក្នុង[38]។

១៦ បន្ថែមពីលើនេះ នៅក្នុងរឿងក្តីនេះ សំណើសុំឱ្យមានកិច្ចស៊ើបអង្កេតចំពោះកិច្ចប្រជុំ*តែភាគីម្ខាង* ដែលរួមមានចៅក្រម Cartwright និង លោក Cayley និង លោក Rosandhaug ។ សំណើសុំបានពិនិត្យច្បាស់លាស់អំពីបទដ្ឋានសីលធម៌ដែលអនុវត្តចំពោះលោក Cayley ហើយបានលើកឡើងថា បទដ្ឋានទាំងនេះ បានហាមឃាត់មិនឱ្យមានកិច្ចប្រជុំបែបនេះទេ[39]។ អង្គបុរេជំនុំជម្រះបានទទួលស្គាល់ពីដំបូងថា ការប្រព្រឹត្តដែលមានជាប់ព័ន្ធនឹងចៅក្រម អាចជាកម្មវត្ថុនៃការស៊ើបអង្កេតផ្អែកតាមវិធាន ៣៥ ទោះបីជាអង្គជំនុំជម្រះមិនមានយុត្តាធិការក្នុងការស៊ើបអង្កេត ឬការដាក់ទណ្ឌកម្មលើចៅក្រមក៏ដោយ[40]។ ហេតុដូច្នេះ បណ្តឹងសាទុក្ខនេះ អាចទទួលយកថា ជាសំណើសុំបំពេញកិច្ចស៊ើបសួរចំពោះការប្រព្រឹត្តរបស់ចៅក្រម Cartwright លោក Cayley និងលោក Rosandhaug។

---

(បណ្តឹងជិតចិត ត្រូវតែមានមូលដ្ឋានអង្គហេតុគាំទ្រ), ១០ (បន្ទុកស្ថិតនៅលើភាគីអនុវត្តដើម្បីផ្តល់ភស្តុតាងដើម្បីបង្ហាញមូលដ្ឋានអង្គហេតុ ចំពោះការចោទប្រកាន់លើភាពលម្អៀង) (មិនមានយុត្តាធិការដើម្បីស៊ើបអង្កេត ផ្អែកតាមវិធាន៣៤ទេ)។

[37] ប្រៀបធៀបវិធាន ៣៥(២)(ក) ដល់ (គ) នៃវិធានផ្ទៃក្នុង (សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ អាចចាត់ការជាមួយបញ្ហានេះជាបន្ទាន់, ដឹកនាំការស៊ើបសួរបន្ថែម ឬបញ្ជូនបញ្ហានេះទៅឱ្យអាជ្ញាធរមានសមត្ថកិច្ច) ជាមួយនឹងសេចក្តីសម្រេចលើពាក្យសុំវិធានការសមស្រប កថាខណ្ឌ ១០ (មានតែលទ្ធផលនៃការអនុវត្តវិធាន៣៤ដោយជោគជ័យប៉ុណ្ណោះ ទើបអាចជិតចិត្តបាន។)

[38] វិធាន ៣៥(៥) នៃវិធានផ្ទៃក្នុង (ទាក់ទងនឹងលទ្ធភាពចាត់វិធានការប្រឆាំងនឹងមេធាវី ផ្អែកតាមវិធាន ៣៥ និង៣៨ ជាមួយគ្នា)។

[39] សំណើសុំ កថាខណ្ឌ ២០, ៣៥។

[40] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាសម្រេចលើសំណើលើកទីពីររបស់លោក នួន ជា សុំឱ្យបំពេញកិច្ចស៊ើបសួរ កថាខណ្ឌ ៤០-៤៤ (ប្រើប្រាស់យុត្តាធិការក្នុងវិធាន៣៥ ទៅលើកិច្ចខិតខំប្រឹងប្រែង ដើម្បីជះឥទ្ធិពលមិនត្រឹមត្រូវលើសហចៅក្រមស៊ើបអង្កេត ប៉ុន្តែមិនមែនលើ "កិច្ចរបស់អង្គជំនុំជម្រះ" ដែលត្រូវបានចោទប្រកាន់ថាកើតចេញពីការប្រើប្រាស់ឥទ្ធិពលនោះទេ)។

១៧ យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា បណ្តឹងសាទុក្ខអាចទទួលយកបាន។

## ខ. **អង្គសេចក្តី**

### ខ.១. វិសាលភាពនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុង

១៨ វិធាន ៣៥ នៃវិធានផ្ទៃក្នុង អនុវត្តចំពោះ "ជនណាម្នាក់" ដែលការប្រព្រឹត្តរបស់ជននោះ "ជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ"។ ទោះបីជាឧទាហរណ៍នៃការប្រព្រឹត្តអំពើបែបនោះ មានចែងនៅក្នុងចំណុច (ក) ដល់ (ច) ក៏ពាក្យពេចន៍"រួមទាំង"នៅក្នុងឃ្លាដំបូងនៃវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង បង្ហាញថា ការរៀបរាប់នេះមិនមានលក្ខណៈបញ្ចូលបុគ្គលទាំងអស់នោះទេ[41]។

១៩ ទោះបីជាយ៉ាងណាក៏ដោយ វិសាលភាពនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុង មិនមែនមិនមានដែនកំណត់នោះទេ។ ការហាមឃាត់ជាក់លាក់នីមួយៗ ដែលមានចែងនៅក្នុងវិធាន ៣៥ ចំណុច (ក) ដល់ (ច) នៃវិធានផ្ទៃក្នុង តម្រូវឲ្យមានការរារាំងអាណត្តិ ឬតួនាទីរបស់តុលាការ។ ចំណុច (ក), (ខ) និង (ង) ពាក់ព័ន្ធនឹងការមិនអនុវត្តដីកាបង្គាប់របស់តុលាការ។ ចំណុច (គ) និង (ឃ) ពាក់ព័ន្ធនឹងការជ្រៀតជ្រែកនឹងភស្តុតាងដែលត្រូវបង្ហាញនៅក្នុងដំណើរការនីតិវិធី ចំពោះមុខតុលាការ។ ចំណុច (ច) ពាក់ព័ន្ធនឹងការជួយដល់ជនជាប់ចោទឲ្យរួចផុតពីយុត្តាធិការរបស់តុលាការ។ អនុលោមតាមវិធាននៃការបកស្រាយលក្ខន្តិកៈអំពីប្រភេទដូចគ្នា (*esjudem generis*) មានតែការប្រព្រឹត្តដែលស្រដៀងគ្នាទៅនឹងមូលដ្ឋានដែលមានចែងទាំងនេះ អាចត្រូវបានពិចារណាក្នុងវិសាលភាពនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុង។ ការវិភាគនេះ ត្រូវបានគាំទ្រដោយអត្ថន័យច្បាស់លាស់នៃពាក្យពេចន៍ "ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ" ដែលបង្ហាញអំពីការខិតខំប្រឹងប្រែងដើម្បីរារាំងដំណើរការ ឬការអនុវត្តដំណើរការនីតិវិធីរបស់តុលាការ[42]។

---

[41] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសេចក្តីប្រកាសព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១ ឯកសារ D14/1/3 កថាខណ្ឌ ២៧។

[42] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Brima និងអ្នកផ្សេងទៀត* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីអនុលោមតាមវិធាន ៧៧ (ញ) ស្តីពីការកម្រិតវិធានការបណ្តោះអាសន្ន និងដីកាសម្រេច អនុលោមតាមវិធាន៧៧(គ)(iii) អង្គជំនុំជម្រះតុលាការកំពូល (SCSL-04-16-AR77) ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៥ កថាខណ្ឌ ២ (អំណាចក្រោមវិធាន៧៧ ដើម្បី

## ខ.២. បទដ្ឋានផ្អែកតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង

២០ វិធាន ៣៤ នៃវិធានផ្ទៃក្នុងចែងថា ភាគីមួយអាចដាក់បណ្ដឹងជំទាស់ចៅក្រម នៅក្នុងករណីណាមួយដែលចៅក្រមរូបនោះ "មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុ ឬមានការពាក់ព័ន្ធ ដែលអាចធ្វើឲ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬអាចបង្កើតឲ្យមានភាពលម្អៀង"។ ចំណុចចុងក្រោយនៃលក្ខខណ្ឌក្នុងវិធាន ៣៤ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងការលេចឡើងភាពលម្អៀង គឺបង្កើតឡើងយ៉ាងច្បាស់នៅក្នុងយុត្តិសាស្ត្រស្ដីពីការដកខ្លួននៅអ.វ.ត.ក[43] ព្រមទាំងនៅតុលាការអន្តរជាតិផ្សេងទៀត[44]។

២១ ទោះបីជាយ៉ាងណាក៏ដោយ ពាក្យពេចន៍បែបនេះ មិនមានទាំងនៅក្នុងបទប្បញ្ញត្តិនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុង និងយុត្តិសាស្ត្រដែលបកស្រាយពាក្យពេចន៍នោះទេ ព្រមទាំងវិធាន ៧៧ នៃវិធាននីតិវិធី និងភស្តុតាងរបស់តុលាការ ICTY និង ICTR ដែលជាពាក្យពេចន៍ស្រដៀងគ្នាមែនទែន នៅតុលាការ *មិនអចិន្ត្រៃយ៍*។ បន្ថែមពីលើនេះ ភាសានៅក្នុងវិធាន៣៥ ដែលចែងការជ្រៀតជ្រែកដោយចេតនាពិតប្រាកដ ក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ គឺមិនស៊ីសង្វាក់គ្នាទៅនឹងបទដ្ឋាន "ការលេចឡើងការជ្រៀតជ្រែក" នោះទេ។ ការលេចឡើងនៃភាពលម្អៀង តម្រូវថា អ្នកសង្កេតការណ៍សមហេតុផលដែលត្រូវបានជូនដំណឹងអំពីកាលៈទេសៈទាំងអស់ នឹងយល់ថា មានការលម្អៀង ប៉ុន្តែការលម្អៀងនោះ មិនទាន់កើតមានពិតប្រាកដនោះទេ[45]។ បទដ្ឋានបែបនោះ មិនអាចស្របគ្នានឹងលក្ខខណ្ឌតម្រូវនៅក្នុងវិធាន ៣៥ នៃវិធានផ្ទៃក្នុងដែលថា ការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ត្រូវតែប្រព្រឹត្តឡើយ "ដោយដឹង និងដោយចេតនា"។

---

ផ្តន្ទាទោសការប្រព្រឹត្តដែលជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ "អាចត្រូវបានប្រើប្រាស់ប្រឆាំងនឹងជនទាំងឡាយដែលអំពើរបស់ជនទាំងនោះ ត្រូវបានគិតថារារាំងកិច្ចការរបស់តុលាការក្នុងការស្វែងរកការពិត")។

[43] សេចក្ដីសម្រេចជាសាធារណៈស្ដីពីបណ្ដឹងជំទាស់ចៅក្រមជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៨ ឯកសារ C11/29 ("សេចក្ដីសម្រេចស្ដីពីបណ្ដឹងជំទាស់ចៅក្រម *ន័យ ថុល*") កថាខណ្ឌ ២០។

[44] សាលដីកាលើរឿងក្ដី *Furundžija* កថាខណ្ឌ ១៨៩។

[45] សេចក្ដីសម្រេចស្ដីពីបណ្ដឹងជំទាស់ចៅក្រម *ន័យ ថុល* កថាខណ្ឌ ២១។ សាលដីកាលើរឿងក្ដី *Furundžija* កថាខណ្ឌ ១៩០។

## ខ.៣. ការអនុវត្តចំពោះរឿងក្តីនេះ

២២ មេធាវីការពារក្តីពុំ "បានលើកឡើងថា មានបញ្ហាណាមួយដែលពុំសមស្របត្រូវបានយកមកពិភាក្សានៅក្នុងអំឡុងពេលនៃកិច្ចប្រជុំទាំងនេះឡើយ"[46]។ ទោះបីជាក្រុមមេធាវីការពារក្តីចោទប្រកាន់ថា កិច្ចប្រជុំ*តែជាមួយនឹងភាគីម្ខាង* បង្កើតជា "អាការៈបង្ហាញនូវការជ្រៀតជ្រែកដោយដឹងនិងដោយចេតនាពិតប្រាកដក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ" ដូចអង្គជំនុំជម្រះបានពន្យល់នៅក្នុងចំណុចខាងលើក៏ដោយ ក៏បទដ្ឋានមួយនេះពុំអាចយកមកអនុវត្តបានឡើយ អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង។

២៣ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ករណីត្រឹមតែថា កិច្ចប្រជុំ*តែជាមួយនឹងភាគីម្ខាង*នៅក្នុងចំណោមចៅក្រម Cartwright លោក Cayley និងលោក Rosandhaug ពុំបង្ហាញហេតុផលជឿថា បុគ្គលណាម្នាក់ក្នុងចំណោមបុគ្គលទាំងនេះ ជ្រៀតជ្រែកដោយចេតនាពិតប្រាកដក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះនោះទេ។ យោងតាមការបកស្រាយរបស់អង្គជំនុំជម្រះលើវិធាន ៣៥ នៃវិធានផ្ទៃក្នុងនោះគឺ មានតែកិច្ចទាំងឡាយណាដែលរារាំងដល់ដំណើរការតុលាការ ទើបស្ថិតនៅក្រោមវិសាលភាពនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុង។ យោងតាមលោក Rosandhaug កិច្ចប្រជុំរបស់ពួកគេពុំមានគោលបំណងបង្អាក់ដំណើរការតុលាការឡើយ ក៏ប៉ុន្តែ វាបានរៀបចំឡើងដើម្បីសម្រួលដល់កិច្ចដំណើរការនីតិវិធីនៃការជំនុំជម្រះតែប៉ុណ្ណោះ។ ក្រុមមេធាវីការពារក្តីពុំជំទាស់នឹងការអះអាងនេះទេ ហើយបានទទួលស្គាល់ថា ក្រុមប្រឹក្សាសម្របសម្រួលដែលដំណើរការនៅតាមបណ្តាសាលាក្តីអន្តរជាតិផ្សេងៗ មានគោលបំណងស្រដៀងគ្នា។ កិច្ចប្រជុំរវាងចៅក្រម Cartwright លោក Cayley បានរៀបចំឡើងរវាង*តែភាគីម្ខាង* កិច្ចប្រជុំទាំងនេះពុំបានប្រែក្លាយដំណើរការសម្របសម្រួលនេះ ឲ្យទៅជា "ការជ្រៀតជ្រែក" ដោយចេតនាពិតប្រាកដ បើទោះជាយោងតាមទទ្បីករណ៍បង្ហាញថា កិច្ចប្រជុំ*តែជាមួយនឹងភាគីម្ខាង* អាចបង្កើតជាការរំលោភលើវិធានជាក់លាក់នៅក្នុងក្រមសីលធម៌វិជ្ជាជីវៈក៏ដោយ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា កិច្ចប្រជុំ*តែជាមួយនឹងភាគីម្ខាង* ដែលក្នុងពេលនោះ ពុំមានបញ្ហាណាមួយមិនសមរម្យបាន

[46] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣០។

កើតឡើង ពុំបង្កើតជាការជ្រៀតជ្រែកដោយចេតនាពិតប្រាកដក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ អនុលោមតាមអត្ថន័យ នៅក្នុងវិធាន ៣៥ នៃវិធានផ្ទៃក្នុងនោះទេ។

២៤ នេះមានន័យថា នៅពេលពុំមានមូលដ្ឋានផ្លូវច្បាប់ណាមួយ ទាំងនៅក្នុងឯកសារបង្កើត អ.វ.ត.ក វិធានផ្ទៃក្នុង ឬ អាណត្តិរបស់អង្គជំនុំជម្រះ និងការិយាល័យ អ.វ.ត.ក សម្រាប់រៀបចំកិច្ចប្រជុំបែបនេះ តំណាងឲ្យតុលាការនោះ កិច្ចប្រជុំបែបនេះអាចត្រូវបានយល់ឃើញថាមានការជាប់ទាក់ទងទៅនឹងរឿងក្តីណាមួយ ឬ រឿងក្តីទាំងឡាយ ដែលចៅក្រមចូលរួមប្រជុំមានការពាក់ព័ន្ធ។ កិច្ចប្រជុំទាំងនេះអាចបង្កើតជាអាការៈបង្ហាញថា សហព្រះរាជអាជ្ញាមានសិទ្ធិចូលរួមប្រជុំ ដូចចៅក្រមជំនុំជម្រះ។ ហេតុដូច្នេះ ដើម្បីជៀសវាងអាការៈបែបនេះ ដែលនាំឲ្យមានបណ្ដឹងដិតចិត្តនោះ វាទំនងជាមានភាពចាំបាច់ត្រូវពិចារណាសមាសភាពនៃកិច្ចប្រជុំទាំងឡាយ ដែលចៅក្រមជំនុំជម្រះមានបំណងចូលរួមជាមួយនឹងព្រះរាជអាជ្ញា ដោយគួរអនុញ្ញាតឲ្យមានការចូលរួមរបស់អង្គភាពគាំពារការការពារក្តី ឬ សមាជិកនៅក្នុងក្រុមមេធាវីការពារក្តី តាមករណីសមស្រប។

**យោងតាមសំអាងហេតុដែលបានរៀបរាប់ខាងលើ** អង្គជំនុំជម្រះតុលាការកំពូល ៖

**សម្រេច** ទទួលយកបណ្តឹងសាទុក្ខនេះ។

**ច្រានចោល** សំណើសុំបើកសវនាការដេញដោលដោយផ្ទាល់មាត់ជាសាធារណៈ និង

**សម្រេច** ច្រានចោលបណ្តឹងសាទុក្ខលើអង្គសេចក្តី។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២

ប្រធានអង្គជំនុំជម្រះតុលាការកំពូល

**គង់ ស្រ៊ីម**